**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់ថវិការង្វាន់ លើការតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្តល់ថវិការង្វាន់ ជូនក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភលើកទឹកចិត្តជូនមន្ត្រីរាជការនៃក្រុមការងារ និងសម្រាប់ចំណាយពង្រឹងយន្តការតឹងទារបំណុល ដោយអនុវត្តគិតចាប់ពីខែមករា ឆ្នាំ២០១៧ តទៅ។

**ប្រការ២ .-**

ការផ្តល់ថវិការង្វាន់ជូនក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍ ត្រូវបានកំណត់ស្មើនឹង ៣%(បីភាគរយ)នៃទឹកប្រាក់បំណុលដែលតឹងទារបាន និងត្រូវបានបែងចែក ដូចខាងក្រោម ÷

- ឧបត្ថម្ភលើកទឹកចិត្តជូនមន្ត្រីរាជការនៃក្រុមការងារចំនួន ៦៥%(ហុកសិបប្រាំភាគរយ)នៃថវិការង្វាន់
- ចំណាយពង្រឹងយន្តការតឹងទារបំណុល និងទំនាក់ទំនងសាធារណៈចំនួន ៣៥%(សាមសិបប្រាំភាគរយ) នៃថវិការង្វាន់។

**ប្រការ៣ .-**

ការផ្តល់ថវិការង្វាន់ក្នុងឆ្នាំនីមួយៗ អាចធ្វើឡើងប្រចាំខែ ឬ ប្រចាំត្រីមាស ឬ សម្រាប់រយៈពេលណាមួយតាមការសម្រេចរបស់ប្រធានក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍។ ការផ្តល់ថវិការង្វាន់នេះ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

- ប្រធានក្រុមការងារតឹងទារបំណុល ត្រូវធ្វើសំណើសុំថវិការង្វាន់ទៅអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវរបាយការណ៍បំណុលដែលតឹងទារបាន និងសលាកប័ត្រចំណូលថវិកាជាតិ ឬ ប័ណ្ណបង់ប្រាក់ ដែលបានបង់ចំណូលចូលថវិកាជាតិ ឬ បង់ប្រាក់ចូលគណនីទោលរបស់រតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា ឬ នៅធនាគារដៃគូ
- អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យសំណុំឯកសារ និងរៀបចំអាណត្តិបើកប្រាក់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចាត់ការបន្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន
- ការបើកផ្តល់ថវិការង្វាន់ជូនក្រុមការងារ ត្រូវផ្ទេរប្រាក់ចូលគណនីរបស់ក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍។

**ប្រការ៤ .–**

ជារៀងរាល់ឆ្នាំ អគ្គលេខាធិការដ្ឋានត្រូវគ្រោងឥណទានចំណាយជំពូក ៦៤ គណនី ៦៤០៣ អនុគណនី ៦៤០៣៣ "រង្វាន់" នៅក្នុងសៀវភៅថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយយោងតាមសំណើរបស់ប្រធានក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍។

ករណីមានបញ្ហាកង្វះឥណទាន ឬ មានឥណទានមិនគ្រប់គ្រាន់ អគ្គលេខាធិការដ្ឋានត្រូវធ្វើសំណើសុំបន្ថែមឥណទាន សម្រាប់ការបើកផ្តល់ថវិការង្វាន់នេះឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

**ប្រការ៥ .–**

ប្រធានក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍ ត្រូវធ្វើរបាយការណ៍ចំណាយថវិការង្វាន់ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .–**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានក្រុមការងារតឹងទារបំណុលមិនមែនសារពើពន្ធក្នុងវិស័យទូរគមនាគមន៍ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ